ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៨ ស្តីពីការតែងតាំងឯកឧត្តម **សុខ គង់** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ដោយមិនទទួលប្រាក់បៀវត្ស ២៣៨១

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៩ ស្តីពីការផ្លាស់ឯកឧត្តម **ខិត សុជាតិ** បច្ចុប្បន្ន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន វិលចូលប្រទេសវិញ ២៣៨២

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨០ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុន ម៉ិយ** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន ២៣៨៣

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ២៣៨៤

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៤ ស្តីពីការតែងតាំងឯកឧត្តម **ណាំ តាលន់** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ ២៣៩០

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៩-៤-២០០៦ -អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ២៣៩១

២០-៤-២០០៦ -អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការកែប្រែមាត្រា ៥ និង មាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការស៊ីរិយោដី ២៣៩៥

១៨-៤-២០០៦ -អនុក្រឹត្យលេខ ២៩២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៣៩៧

១៨-៤-២០០៦ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៩៨

១៨-៤-២០០៦ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៤០០

១៨-៤-២០០៦ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៤០២

១៨-៤-២០០៦ -អនុក្រឹត្យលេខ ២៥៦ អនក្រ.បក ស្ដីពីការតែងតាំងបន្ថែមសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ២៤០៥

១៩-៤-២០០៦ -អនុក្រឹត្យលេខ ២៥៧ អនក្រ.បក ស្ដីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ២៤០៧

១៩-៤-២០០៦ -អនុក្រឹត្យលេខ ២៥៨ អនក្រ.បក ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៤០៨

២១-៤-២០០៦ -អនុក្រឹត្យលេខ ២៥៩ អនក្រ.បក ស្ដីពីការតម្លើងការិយាល័យនគរបាលអន្តរជាតិ ទៅជានាយកដ្ឋាននគរបាលអន្តរជាតិនៃក្រសួងមហាផ្ទៃ ២៤០៩

២១-៤-២០០៦ -អនុក្រឹត្យលេខ ២៦០ អនក្រ.បក ស្ដីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៤១២

២១-៤-២០០៦ -អនុក្រឹត្យលេខ ២៦១ អនក្រ.បក ស្ដីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៤១៣

២១-៤-២០០៦ -អនុក្រឹត្យលេខ ២៦២ អនក្រ.បក ស្ដីពីការតែងតាំងមុខងារ នាយទាហាន ២៤១៤

២១-៤-២០០៦ -អនុក្រឹត្យលេខ ២៦៣ អនក្រ.បក ស្ដីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ២៤១៦

២_សារាចរណែនាំ

២០-៤-២០០៦ -សារាចរណែនាំលេខ ០៤ សរណន ស្ដីពីការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០០៦ ២៤១៩

IV_ការងារបណ្ដាក្រសួង

១_លិខិតការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១០-៣-២០០៦ -លិខិតលេខ ៧១៩ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ោយម៉ែត អិចផត** ២៤២១

១០-៣-២០០៦ -លិខិតលេខ ៧២០ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេសេសស៊ី ថេកណូឡូជី** ២៤២៣

១០-៣-២០០៦ -លិខិតលេខ ៧៣០ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ័ត្ត ទេនឈាំរ ខេមបូឌាន អ៊ីន** ២៤២៥

១០-៣-២០០៦ -លិខិតលេខ ៧៣១ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូនីម៉ោរ អ៊ីន** ២៤២៧

១៤-៣-២០០៦ -លិខិតលេខ ៧៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិសិដ្ឋ ស៊ូនី គ្រុប** ២៤២៩

១៤-៣-២០០៦ -លិខិតលេខ ៧៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.ស៊ី.ត៊ី ហ្វាម៉ា** ២៤៣១

១៤-៣-២០០៦ -លិខិតលេខ ៧៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មីសាមគ្គី ២០០០** ២៤៣៣

១៤-៣-២០០៦ -លិខិតលេខ ៧៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូណាយធីត ស៊ុលស្ទ្រីន ត៊ីធីអ៊ី អិលធីឌី** ២៤៣៥

១៤-៣-២០០៦ -លិខិតលេខ ៧៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វេង ស៊ុន លី ខូ អិលធីឌី** ២៤៣៧

១៤-៣-២០០៦ -លិខិតលេខ ៧៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ណាយស៍ អ៊ិនខបភើរេសិន** ២៤៣៩

១៤-៣-២០០៦ -លិខិតលេខ ៧៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិន អេច អេហ្វ** ២៤៤១

១៥-៣-២០០៦ -លិខិតលេខ ៧៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តុង គួង ហេង អ៊ិមផត អិចផត** ២៤៤៣

១៥-៣-២០០៦ -លិខិតលេខ ៧៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម គ្រីស្ទីនែរ ធួរ** ២៤៤៥

១៥-៣-២០០៦ -លិខិតលេខ ៧៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ើស មេគង្គ** ២៤៤៧

១៥-៣-២០០៦ -លិខិតលេខ ៧៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី.អេស.ត៊ី (ខេមបូឌា)** ២៤៤៩

១៥-៣-២០០៦ -លិខិតលេខ ៧៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វង់ គំរូ ប៊ុរី ត្រេនស្ព័ត** ២៤៥១

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម សុខ គង់ ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ដោយមិនទទួលប្រាក់បៀវត្ស ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៦០៤.១៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៦

លេខ: ១៧៤ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ តាន់

នស/រកត/០៤០៦/១៧៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្លាស់ឯកឧត្តម ឱក សុជាតិ បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន វិលចូលប្រទេសវិញ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៦០៤.១៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០០៦

លេខៈ ១៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម អ៊ិន ម៉យ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៦០៤.១៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០០៦ លេខៈ ១៧៣ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៣

ស្តីពី

ការកំណត់មណ្ឌលដ្ឋានប្រាសាទព្រះវិហារ

~~~~~~~

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
~~~~~~~

គ្រាសបន្ទាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានប្រកាសកំណត់តំបន់រមណីយដ្ឋានវប្បធម៌ នៃប្រាសាទព្រះវិហារជារមណីយដ្ឋានការពារស្ថិតនៅលើភ្នំព្រះវិហារ នៃជួរភ្នំដងរែកក្នុងភូមិសាឯម (អតីតភូមិស្វាយជ្រុំ) ឃុំកន្ទួត ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ។

មាត្រា ២.-

ការបង្កើតរមណីយដ្ឋានការពារនេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និងលើកកំពស់តម្លៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្សទេសភាពវប្បធម៌ និងអភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

ជំពូកទី ២

ការកំណត់តំបន់

មាត្រា ៣.-

តម្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និងការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ ។

មាត្រា ៤.-

រមណីយដ្ឋានការពារប្រាសាទព្រះវិហារ ត្រូវចាត់ជា ៤ (បួន) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - តំបន់ទី ១ : ជាតំបន់រមណីយដ្ឋានមានប្រាសាទ ហៅថា តំបន់ស្នូល មានផ្ទៃក្រឡាសរុប ១៥៤.៧ ហិកតា កំណត់យកតួភ្នំទាំងមូល គិតចាប់ពីកំពូលភ្នំនៃប្រាសាទព្រះវិហារ ដែលមានខ្សែរយៈកំពស់ ៦២៥ ម៉ែត្រ ចុះក្រោមរហូតដល់ខ្សែរយៈកំពស់៥០០ម៉ែត្រ កំណត់ដោយចំណុចដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយ ដូចតទៅ :

ចំណុច	រយៈទទឹង			រយៈបណ្តោយ		
1	14°	23'	59"	104°	41'	30"
2	14	23	41	104	41	20
3	14	23	28	104	41	18
4	14	23	13	104	41	07
5	14	23	18	104	40	52
6	14	23	27	104	40	41
7	14	23	44	104	40	33
8	14	23	49	104	40	34
9	14	23	50	104	40	41

និងខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ រាប់បញ្ចូលទាំងជណ្តើរប្រវត្តិសាស្ត្រ ដែលស្ថិតនៅចំហៀងខាងកើតភ្នំ ហើយដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយ ដូចតទៅ :

ចំណុច	រយៈទទឹង			រយៈបណ្តោយ		
T	14°	23’	16’’	104°	42’	12’’
2	14	23	41	104	41	20
10	14	23	41	104	41	05

ដោយត្រូវរក្សាការពារចំណីជណ្តើរ ៥០ ម៉ែត្រ សង្ខាងជណ្តើរផងដែរ ។

តំបន់នេះ ជាតំបន់មានប្រាសាទព្រះវិហារសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - តំបន់ទី ២ : ជាតំបន់អភិរក្សឧទ្យានបុរាណវត្ថុ និងទេសភាពវប្បធម៌ បរិស្ថានធម្មជាតិ ហៅថាតំបន់ទ្រនាប់ដែលមានផ្ទៃក្រឡាសរុប ២៦៤២.៥ ហិកតា ។

តំបន់នេះ ត្រូវបានកំណត់យកផ្ទៃដីចន្លោះខ្សែបន្ទាត់ បរិវេណនៃតំបន់ស្នូល និងខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ ហើយនិងខ្សែបន្ទាត់អ័ក្សផ្លូវដែលចាប់ផ្តើមពីមាត់ច្រកតំបន់ព្រំដែនតាថាវ តាមបណ្តោយផ្លូវកាត់តាមបណ្តាចំណុច T, B, C (ភូមិ ត១)និង D បត់ឡើងទៅលើភ្នំប្រាសាទព្រះវិហារ រហូតដល់ខ្សែកំពស់ ៥០០ ម៉ែត្រ ហើយដែលមានខ្សែរយៈទទឹង និង ខ្សែរយៈបណ្តោយ ដូចខាងក្រោម :

ចំណុច	រយៈទទឹង			រយៈបណ្តោយ		
B	14°	22’	19”	104°	42’	48”
C	14	22	34	104	40	02
D	14	23	22	104	40	08
T	14	23	16	104	42	12

ក៏ត្រូវបានរាប់បញ្ចូលក្នុងតំបន់ទី ២ ផងដែរ នូវតំបន់ដែលមានផ្ទៃដីកំណត់ដោយមុំ ៦០ អង្សារ ដែលមានចំណុចផ្តើម O ស្ថិតនៅខ្សែរយៈកំពស់ ៦២៥ ម៉ែត្រលើកំពូលភ្នំប្រាសាទព្រះវិហារ បែរមុខត្រង់ឆ្ពោះទៅទិសខាងត្បូង ហើយមានបន្ទាត់ខ្សែរយៈបណ្តោយ ជាបន្ទាត់បែងចែកមុំពាក់កណ្តាលស្មើគ្នា ។ ខ្សែបន្ទាត់មុំ O ទាំងពីរកាត់អ័ក្សផ្លូវ B, C បានជាចំណុច F, G ហើយកាត់រង្វង់មូលកោងដែលមានកាំចម្ងាយប្រវែង ៥ គីឡូម៉ែត្រ បានជាចំណុច L, K ដែលមានខ្សែរយៈទទឹង និង ខ្សែរយៈបណ្តោយ ដូចខាងក្រោម :

ចំណុច	រយៈទទឹង			រយៈបណ្តោយ		
O	14°	23’	18”	104°	41’	02”
F	14	22	37	104	40	39
G	14	22	29	104	41	32
K	14	20	56	104	42	29
L	14	20	55	104	39	40

តំបន់ទី ២ ដែលជាឧទ្យានបុរាណវត្ថុត្រូវការពារ ដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជាអចលនទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ រាល់ការលក់ដូរ ដោះដូរ ឬ សម្បទានអ្វីមួយទៅលើដីធ្លី ដែលស្ថិតក្នុងតំបន់ទី ២ ត្រូវចាត់ទុកជាមោឃៈ ។

តំបន់នេះសម្បូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារទប់ស្កាត់ ការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍមិនសមស្រប ។

គ -តំបន់ទី ៣ : ជាតំបន់អភិវឌ្ឍនិវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់រណប មានផ្ទៃក្រឡា សរុប ២.៨២៨.៩ ហិកតា ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទម្លាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ស្រោប ។

តំបន់ទី ៣ នេះ ត្រូវបានចែកជា ២ (ពីរ) តំបន់ដាច់គ្នា គឺ តំបន់ទី ៣ក ដែលមានផ្ទៃក្រឡា ៦៧៩.១ ហិកតា និងតំបន់ទី ៣ខ ដែលមានផ្ទៃក្រឡា ១១៤៩.៨ ហិកតា ។

ដីធ្លីទាំងអស់ដែលស្ថិតនៅក្នុងតំបន់ទី ៣ ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ គឺជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ រាល់បណ្តាគំរោងអភិវឌ្ឍន៍ ក្នុងតំបន់ ៣ក និង ៣ខ ត្រូវអនុវត្តតាមប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និងបទប្បញ្ញត្តិពិសេសទាំងឡាយដែលពាក់ព័ន្ធ ដល់ការរៀបចំអភិវឌ្ឍន៍ នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិតាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចីរភាព និងមានការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន ។

ឃ-តំបន់ទី ៤ : ជាតំបន់ដែលតម្រូវឱ្យមានការអភិរក្សធនធានធម្មជាតិ អនុវត្តន៍តាមព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង តាមព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ រួមទាំងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "ព្រះវិហារ" ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

ជំពូកទី ៣
ការគ្រប់គ្រង ថែទាំ និង ការពារ

មាត្រា ៥.-

ការអភិរក្សតំបន់នីមួយៗ ត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យនេះ និង គិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតម្លៃកាន់តែប្រសើរឡើង ។

មាត្រា ៦.-

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ចដែលមានក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ។

យោងលើមាត្រា ៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ នៅតំបន់ប្រាសាទព្រះវិហារ ការការពារថែរក្សា និងលើកតម្លៃ

បេតិកភ័ណ្ឌវប្បធម៌ជាតិ ត្រូវប្រគល់ឱ្យអាជ្ញាធរមួយ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់ប្រាសាទព្រះវិហារ ដែលនឹងត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

អាជ្ញាធរនេះ ត្រូវទទួលភារកិច្ចផ្តាច់មុខ ជាអ្នកចាត់ចែងពិធីគ្រប់ជំពូកទាំងអស់ ក្នុងបរិវេណរមណីយដ្ឋានប្រាសាទព្រះវិហារ ។ ដើម្បីបំពេញបេសកកម្មទាំងនេះបាន អាជ្ញាធរមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ចំពោះការស្ថាបនាទាំងឡាយក្រៅបរិវេណការពាររមណីយដ្ឋានប្រាសាទព្រះវិហារ ។

ការអនុញ្ញាតសាងសង់ ដែលចេញដោយអាជ្ញាធរផ្សេងពីអាជ្ញាធរខាងលើ ទាក់ទងនឹងសំណង់នៅរមណីយដ្ឋាន ត្រូវចាត់ទុកជាមោឃៈ ។

បែបបទ និងនីតិវិធី នៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧.-

បរិវេណ និងរាល់សកម្មភាពនៅក្នុងតំបន់នីមួយៗ នៃរមណីយដ្ឋានការពារប្រាសាទព្រះវិហារ អាចត្រូវបានពិនិត្យឡើងវិញ ហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

មាត្រា ៨.-

ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៥ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

នស/រកត/០៤០៦/១៩៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខៈ ១៤២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

១/៤


1:55000
1 14°23'59'' 104°41'30''
2 14 23 41 104 41 20
3 14 23 28 104 41 18
4 14 23 13 104 41 07
5 14 23 18 104 40 52
6 14 23 27 104 40 41
7 14 23 44 104 40 33
8 14 23 49 104 40 34
9 14 23 50 104 40 41
10 14 23 41 104 41 05
14 21 49 104 39 29
14 23 18 104 41 02
SPOT
GPS

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៤

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឈាំ តាលន់ ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៦០៤.១៩៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខ: ១៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឆាវី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៣...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- យោងអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួលលើ មាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងសេចក្ដីជូនដំណឹងលេខ ២៦៨ សជណ.សរ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីលទ្ធផលនៃសម័យប្រជុំច្រកចេញ-ចូលតែមួយនៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ** (PHNOM PENH SEZ) ដែលមានទីតាំងស្ថិតនៅចន្លោះឃុំភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងឃុំកន្ទោក-ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

មាត្រា២.-

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ មានទំហំ បីរយហាសិបហិកតា និងដប់ម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

មាត្រា៣.-

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជន ស្របច្បាប់របស់ក្រុមហ៊ុន ។

មាត្រា៤.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទបញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ-រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ-អភិបាលរាជធានីភ្នំពេញ-អភិបាលខេត្តកណ្តាល និងក្រុមហ៊ុន ភ្នំពេញអេសអ៊ី ហ្សិតខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្ដីជម្រាបជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា
អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស

សុខ ចិន្តា

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៥ ដើម្បីសហការអនុវត្ត
- ឯកសារ-កាលប្បវត្តិ



តារាងកូអរដោនេនៃចំណុចព្រំដីតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

Points	Northing	Easting	Points	Northing	Easting
001	1273556.848	475943.224	079	1269220.350	476028.630
002	1273516.563	475950.442	080	1269345.098	476019.048
003	1273509.952	475944.971	081	1269369.066	476016.084
004	1273508.293	475945.255	082	1269639.137	476016.881
005	1273491.694	475939.511	083	1269662.672	476010.923
006	1273486.459	475933.735	084	1269684.578	476003.127
007	1273466.280	475935.428	085	1270182.343	475977.414
008	1273465.048	475922.146	086	1270453.610	475901.600
009	1273459.393	475917.744	087	1270602.941	475939.012
010	1273409.691	475941.037	088	1269171.550	476104.690
011	1273345.697	475966.598	089	1269188.500	476614.260
012	1273269.203	475977.565	090	1269243.970	476632.020
013	1273204.309	475995.921	091	1269259.380	476744.230
014	1273186.844	476133.103	092	1269258.430	476799.200
015	1272997.839	476134.330	093	1268326.450	476569.900
016	1272856.045	476147.047	094	1268325.750	476047.210
017	1272509.705	476162.220	095	1268909.538	476059.459
018	1272433.960	476159.260	096	1268924.059	476073.979
019	1272360.540	475546.620	097	1269023.912	476078.381
020	1272497.651	475523.496	098	1269170.692	476070.398
021	1272580.952	475671.601	099	1268314.440	476567.250
022	1272584.368	475748.986	100	1268075.767	476506.297
023	1272800.832	475786.532	101	1268077.002	476485.086
024	1272939.155	475803.652	102	1267963.672	476481.825
025	1272957.551	475834.834	103	1267793.060	476440.480
026	1273007.735	475846.934	104	1267796.033	476412.214
027	1273154.487	475858.313	105	1267731.200	476408.940
028	1273205.514	475869.051	106	1267725.160	476312.010
029	1273327.467	475883.795	107	1267743.605	476314.535
030	1273349.667	475886.651	108	1267799.391	476321.521
031	1273393.395	475880.869	109	1267866.010	476356.900
032	1273394.169	475845.977	110	1267997.740	476360.440
033	1273462.590	475825.120	111	1268000.615	476040.102
034	1273509.899	475804.770	112	1268313.750	476046.920
035	1272427.990	476159.800	113	1267703.381	476416.868
036	1272343.137	476156.574	114	1267291.198	476314.913
037	1271910.640	476089.540	115	1266904.179	476219.822
038	1271903.119	476165.976	116	1266471.680	476112.680
039	1271905.080	476250.304	117	1266521.140	475919.070
040	1271695.037	476264.471	118	1266577.424	475936.625
041	1271466.012	476272.124	119	1266590.252	475917.341
042	1271122.095	476292.429	120	1266689.560	475929.660
043	1271073.582	476291.356	121	1266708.840	475833.900
044	1271066.990	476290.050	122	1266638.858	475827.882
045	1270938.960	475789.360	123	1266724.060	475761.717
046	1271837.887	475557.631	124	1266726.346	475745.378
047	1272318.817	475448.784	125	1266734.477	475741.900
048	1272332.092	475459.752	126	1266737.148	475719.025
049	1272374.627	475547.821	127	1266744.588	475693.929
050	1270962.070	475901.220	128	1266767.319	475660.254
051	1270758.022	475917.619	129	1266761.627	475661.032
052	1270667.500	475930.106	130	1266759.589	475634.139
053	1270664.489	475838.608	131	1266779.790	475632.190
054	1270928.240	475785.950	132	1266761.540	475603.070
055	1271063.880	476290.080	133	1266652.590	475591.280
056	1270829.111	476256.990	134	1266652.360	475486.730
057	1270809.075	476144.347	135	1266770.922	475454.607
058	1270790.037	476117.375	136	1266775.895	475455.123
059	1270600.850	476088.980	137	1266813.8[illegible]	475459.067
060	1270627.995	476230.220	138	1266815.591	475441.537
061	1270674.609	476216.510	139	1266942.182	475464.015
062	1270698.030	476341.899	140	1267069.890	475556.720
063	1270564.758	476390.504	141	1267202.180	475688.340
064	1270527.490	476411.620	142	1267255.080	475887.550
065	1270519.969	476386.330	143	1267312.070	475965.790
066	1270383.241	476399.027	144	1267405.580	475980.820
067	1270237.290	476369.638	145	1267476.160	475979.800
068	1270036.709	476333.542	146	1267463.767	475999.365
069	1270005.095	476455.028	147	1267455.714	476026.425
070	1269965.892	476579.286	148	1267446.920	476110.550
071	1269922.198	476705.077	149	1267536.610	476131.260
072	1269940.666	476839.343	150	1267535.440	476146.770
073	1269869.532	476861.977	151	1267565.990	476154.040
074	1269662.524	476944.213	152	1267575.630	476281.510
075	1269547.041	476869.966	153	1267608.467	476281.139
076	1269306.240	476810.780	154	1267623.242	476329.260
077	1269309.410	476742.700	155	1267650.175	476333.729
078	1269221.050	476072.410	156	1267695.810	476336.290

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦
... និង ...
ពឹម រ៉ាដ

បានពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ២៥ ខែ ... ឆ្នាំ ២០០៦
ប្រធាននាយកដ្ឋានបច្ចេកទេស

ភ្នំពេញ ថ្ងៃទី ២៤ ខែ ... ឆ្នាំ ២០០៦
ប្រធានក្រុមវាស់វែង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការកែប្រែមាត្រា ៥ និង មាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ ៖ មាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ៥ ថ្មី : គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូប ដែលជាអភិបាលស្រុក ខណ្ឌ និង អនុប្រធានមួយរូប ដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាល ស្រុក ខណ្ឌ ជាសមាជិក ។

ប្រធានគណៈកម្មការសុរិយោដីនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដី ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និងចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក ។

មាត្រា ២៨ ថ្មី : - គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក ខណ្ឌ ។

- គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។
- គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -គ្រប់សាលាខេត្ត ក្រុង
- -ដូចមាត្រា ៣
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីដឹកនាំខេត្ត នាយទាហាន និង នាយនគរបាលជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន ០៨ រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជួយឧបត្ថម្ភ ដល់កងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម LE THANH HAI ប្រធានគណៈកម្មាធិការប្រជាជន ទីក្រុងហូជីមិញ
២-ឯកឧត្តម TRAN MINH SANH ប្រធានគណៈកម្មាធិការប្រជាជន ខេត្តបារៀ. វុងតាវ
៣-ឯកឧត្តម NGUYEN VAN HIEP ប្រធានគណៈកម្មាធិការប្រជាជន ខេត្តប៊ិញ យឿង
៤-ឯកឧត្តម HUYNH CHI THANG អនុប្រធានគណៈកម្មាធិការប្រជាជន ខេត្តដុងណាយ
៥-លោកវរសេនីយ៍ឯក NGUYEN VAN MANH នាយរងសេនាធិការ យោធភូមិភាគទី៧ នៃសាធារណរដ្ឋសង្គមនិយម វៀតណាម ។
៦-លោកវរសេនីយ៍ឯក HUYNH TAN KIET ប្រធានការិយាល័យចារកម្មយោធភូមិភាគទី៧ នៃសាធារណរដ្ឋ សង្គមនិយមវៀតណាម ។
៧-លោកវរសេនីយ៍ឯក NGUYEN THE HANH នាយករងសាលាមធ្យមសិក្សាសន្តិសុខប្រជាជនទី២ នៃក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយម វៀតណាម។

៨-លោកវរសេនីយ៍ឯក PHAM VAN CHUYEN នាយករងសាលាមធ្យមសិក្សាសន្តិសុខប្រជាជនទី២ នៃក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយម វៀតណាម ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូន លោកឧត្តមសេនីយ៍ត្រី **ហេង ឧត្តី** នាយករងទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អ ក្នុងការស្វែងរកជំនួយមកឧបត្ថម្ភដល់ការកសាង និង អភិវឌ្ឍន៍ប្រទេសជាតិ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៣៧
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៨រូប ដែលបានផ្តល់អំណោយជារថយន្ត ចំនួន ០៧ គ្រឿង ត្រាក់ទ័រចំនួន ៥០ គ្រឿង គោយន្តចំនួន ៥០គ្រឿង និងម៉ាស៊ីនបូមទឹកចំនួន ២០០គ្រឿង មានតម្លៃជាទឹកប្រាក់ចំនួន ៣៦៤.២៤៤ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១- Excellency. CAO BO CHUN Secretary, Guangxi Zhuang Autonomous Region Committee of China Communist part (មកពីសាធារណរដ្ឋប្រជាមានិតចិន)

២- Excellency. LU BING Chairman, Peopte ' s Government China Guangxi Zhuang Autonomous Region (មកពីសាធារណរដ្ឋប្រជាមានិតចិន)

៣- Mr. SHA XIAO YONG General Manager China Guangxi Corporation for International Techno-Economic Coorperation (មកពីសាធារណរដ្ឋប្រជាមានិតចិន)

៤- Mr. DENG ZHANG WANG Manager Cambodia Branch of China Guangxi Corporation for International Techno-Economic Coorperation (មកពីសាធារណរដ្ឋប្រជាមានិតចិន)

៥- Mr. CHO KU HO President 0f UGRG Co.,Ltd. (មកពីសាធារណរដ្ឋកូរ៉េ)

៦- Mr. ERNEST MARCUS LAI Manager of Vanny BIO-Research (Cambodia) Co.,Ltd. (មកពីហុងកុង)

៧- Mr. KIM DEA BONG SEOUL CITY SAEDAMOON GU CANDIDAT.
(មកពីសាធារណរដ្ឋកូរ៉េ)

៨- លោកឧត្តមសេនីយ៍ត្រី **ហេង ឫទ្ធី** នាយករងទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការ
នៃកងយោធពលខេមរភូមិន្ទ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការស៊ីវិលនៅខេត្តកំពង់ធំ ចំនួន ៣៩ នាក់ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០៥ ដូចមានរាយនាមខាងក្រោមនេះ :

ក_ មេដាយមាសការងារ

១-លោក	គង់ ទិមាន	អភិបាលរងទី ១ ខេត្តកំពង់ធំ
២-លោក	អ៊ុខ ឆាយ	អភិបាលរងទី ៣ ខេត្តកំពង់ធំ
៣-លោក	ហុក សឿន	អភិបាលរងខេត្តកំពង់ធំ
៤-លោក	ហួត សុគុណា	អភិបាលរងខេត្តកំពង់ធំ

ខ_ មេដាយប្រាក់ការងារ

១-លោក	ស្រ៊ី សារីន	នាយក្រុមហិរញ្ញវត្ថុសាលាខេត្តកំពង់ធំ
២-លោក	ស គឹមសេង	នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តកំពង់ធំ
៣-លោក	ស៊ាន សៀវហោ	អភិបាលរងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

ខ_ មេដាយសេរីវត្តិការងារ

១-លោក	ពេជ សុធា	អធិការរង នៃក្រុមអធិការកិច្ចសាលាខេត្តកំពង់ធំ
-លោកស្រី	ដៀប ប៉ូលី	នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តកំពង់ធំ
៣-លោក	ស៊ិន ខាន់	អធិការរង នៃក្រុមអធិការកិច្ចសាលាខេត្តកំពង់ធំ
